ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# សុន្ទរកថា

ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី

ប្រធានអាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍

ក្នុងឱកាសបើក

**សិក្ខាសាលាថ្នាក់ជាតិផ្ទៀងផ្ទាត់លទ្ធផលនៃការរៀបចំរបាយការណ៍សកលនៃការឆ្លើយតបទៅ**

**នឹងមេរោគអេដស៍និងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា**

ថ្ងៃទី ១០ មេសា ឆ្នាំ២០១៥ សណ្ឋាគារ សាន់វេ

- ឯកឧត្តម លោកជំទាវ និង គណៈអធិបតី
- លោកស្រី Marie-Odile Emond, Country Director, UNAIDS, Cambodia ប្រធានអង្គការ UNAIDS ប្រចាំប្រទេសកម្ពុជា
- លោកវេជ្ជ. អ៊ុក វិជ្ជា តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាម រោគ។
- លោក ទឹម រ៉ា តំណាងអង្គការសង្គមស៊ីវិល
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា តំណាងស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ។
- លោក លោកស្រី អ្នកនាងកញ្ញា តំណាងអង្គការ មិនមែនរដ្ឋាភិបាល ជាតិ អន្តរជាតិ ដៃគូរអភិវឌ្ឍន៍និង សង្គមស៊ីវិល ។

- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា សមាជិកអង្គសិក្ខាសាលាទាំងអស់ជាទីរាប់អាន ។

ជាបឋមក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណជាអនេក ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែល បានឆ្លៀតឱកាសដ៏មមាញឹកអញ្ជើញចូលរួមនៅក្នុងអង្គសិក្ខាសាលាដ៏មានសារៈសំខាន់នាពេល នេះ ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា

សិក្ខាសាលាថ្នាក់ជាតិផ្សៀងផ្ទាត់លទ្ធផលនៃការរៀបចំរបាយការណ៍សកលនៃការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជាថ្ងៃនេះគឺផ្តោតលើការតាមដានការឆ្លើយ តប និង វាស់វែងវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅ ឆ្លើយតបទៅនឹងមេរោគអេដស៍ និង ជំងឺ អេដស៍ ។ ដូចនេះយើងនឹងពិភាក្សាលើសូចនាករដែលទាក់ទងនឹងការឆ្លើយតប ទៅនឹងមេរោគ អេដស៍និងជំងឺអេដស៍។

ដូចយើងទាំងអស់គ្នាដឹងហើយថា៖

- សូចនាករទាក់ទងកម្មវិធី
- ហើយកម្មវិធីទាក់ទងគោលនយោបាយ
- ហើយគោលនយោបាយទាក់ទងថវិកា។

<u>ចំពោះសូចនាករ</u>

- តើយើងត្រូវការសូចនាករអ្វីខ្លះ? ប្រការនេះខ្ញុំសូមលើកពាក្យមួយឃ្លារបស់លោកអាល់ប៊ឺតអែស្តាញដែលថា:“អ្វីគ្រប់យ៉ាងដែលអាចត្រូវបានរាប់មិនមែនសុទ្ធតែមានប្រយោជន៍ទេ ។ ហើយអ្វីដែលមានប្រយោជន៍មិនមែនសុទ្ធងាយស្រួលក្នុងការគណនាឬរាប់ចំនួននោះឡើយ”(“Everything that can be counted does not

necessarily count; everything that counts cannot necessarily be counted" Albert Einstein)។

- ខ្ញុំសូមបញ្ជាក់ផងដែរថា ការដែលយើងធ្វើរបាយការណ៍អំពីវឌ្ឍនៈភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ ជំងឺអេដស៍ជូនអង្គការសហប្រជាជាតិនេះគឺ មានសារៈប្រយោជន៍ ក្នុងការតាមពិនិត្យមើលលទ្ធផលនៃការអនុវត្តន៍កម្មវិធីអេដស៍របស់យើង ដើម្បីឲ្យបានដឹងថាយើងស្ថិតនៅក្នុងស្ថានភាពបែបណា និង ត្រូវបង្កើនការឆ្លើយតបយ៉ាងដូចម្តេច ក្នុងករណីដែលយើងមិនសំរេចបានទៅតាមផែនការនោះ ។
- ឯកឧត្តម លោកជំទាវ លោក លោកស្រី បានដឹងស្រាប់ហើយថាចាប់ទាំងពី ឆ្នាំ ២០០១ អង្គការសហប្រជាជាតិ បានសម្រេចក្នុងកិច្ចប្រជុំជាពិសេសអំពីបញ្ហាអេដស៍របស់ ប្រទេសជាសមាជិកថាប្រទេសទាំងអស់ត្រូវរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តកម្ម- វិធីអេដស៍ នៅក្នុងប្រទេសនីមួយៗរៀងរាល់២ឆ្នាំម្តង កាលនោះ គេហៅថា UNGASSជាភាសារអង់គ្លេស ។ ខ្ញុំសូមឆ្លៀតឱកាសនេះបញ្ជាក់ជូនអង្គសិក្ខាសាលាផងដែរថានៅ ឆ្នាំ ២០១១ របាយការណ៍ UNGASS នេះ បានប្តូរឈ្មោះមកជា GARPR វិញ ។ ទោះ ជាយ៉ាងណាក៏ដោយទាំង UNGASS ទាំង GARPR មានគោលបំណងឃ្លាំមើលការរីក ចំរើននៃការឆ្លើយតបក៏ដូចជាលទ្ធផលដែលទទួលបានពីការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើទូទាំងសកលលោក។
- ការធ្វើរបាយការណ៍បានចាប់ផ្តើមឡើងនៅឆ្នាំ ២០០៤ គឺធ្វើជារៀងរាល់ពីរឆ្នាំជាទៀងទាត់រហូតដល់ឆ្នាំ ២០១៣។ នៅឆ្នាំ ២០១៣ នោះ មានការការប្រែប្រួលមួយដោយខាងកម្មវិធីអេដស៍នៃអង្គការសហប្រជាតិ បានតម្រូវឲ្យប្រទេសជាសមាជិកត្រូវរាយការណ៍ជារៀងរាល់ឆ្នាំវិញ ។ លើសពីនេះទៅទៀតនោះគឺថា ការមានសូចនាករខ្លះដែលតម្រូវអោយរាយការណ៍ប្រចាំ ឆមាសផងដែរ ។
- ជារួមប្រទេសសមាជិកទាំងអស់មានការចូលរួមធ្វើរបាយការណ៍ GARPR នេះកើនឡើងជាលំដាប់ចាប់ពី១០២ប្រទេស (៥៣%) មក ១៨០ ប្រទេស (៩៣%) នៅឆ្នាំ ២០១៤ ។

ចំពោះកម្មវិធី

- ដូចដែល ឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបហើយថាប្រទេសកម្ពុជាយើងបានប្តេជ្ញាបញ្ចប់ការចំឡងថ្មីនៅក្នុងឆ្នាំ២០២០ ដែលជាការសំរេចចិត្តប្រកបដោយ ភាពក្លាហានព្រោះថា យើងឈានលឿនជាងពិភពលោក១០ឆ្នាំដោយសកលលោក ទាំងមូលនឹងបញ្ចប់ការចំឡងថ្មីនៅក្នុងឆ្នាំ ២០៣០ ។
- ដូចនេះយើងនឹងត្រូវជាប្រទេសទីមួយនៅក្នុងតំបន់ដែលនឹងត្រូវសំរេចគោលដៅ90-90-90 មុនគេបង្អស់ ។ នោះមានន័យថា90%នៃប្រជាជនដែលរស់នៅជាមួយមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន, 90% នៃមនុស្សដែលរស់នៅជា មួយមេរោគអេដស៍ដែលទទួលការព្យាបាលប្រឆាំងនឹងមេរោគអេដស៍, និង 90% នៃអ្នកដែលទទួលការការព្យាបាលគ្មានបន្ទុកមេរោគអេដស៍ទៀតឡើយ។

ចំពោះគោលនយោបាយ

- ជាទូទៅយើងត្រូវការទាំងទិន្នន័យនិងព័ត៌មាន ចាប់ពីថ្នាក់កម្មវិធីរហូតដល់ការគ្រប់គ្រងនិង ការរៀបចំគោលនយោបាយ ។ ដោយឡែកនៅឆ្នាំ ២០១៥ នេះ មិនតម្រូវឲ្យយើងរាយការណ៍អំពី National Committment on Policy Instrument NCPI ឧបករណ៏ កំណត់គោលនយោបាយទេ។
- ចំពោះប្រទេសកម្ពុជាយើងបានរាយការណ៍ជាទៀងទាត់ ចាប់តាំងពីឆ្នាំ ២០០៤ រហូតមកដល់ពេលនេះ ។

ចំពោះថវិកា

- ខ្ញុំសូមជំរាបឯកឧត្តម លោក ជំទាវ លោក លោកស្រីផងដែរថាប្រទេសកម្ពុជាយើងកំពុង
ស្ថិតក្នុងស្ថានភាពដែលថវិកា ជំនួយត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ ក្រោមហេតុផល ២យ៉ាង គឺ ៖

- o ប្រទេសកម្ពុជាជាប្រទេសដែលមានអត្រាផ្ទុកមេរោគអេដស៍ ក្នុងចំណោមប្រជាជនទូទៅ ទាបជាង ១% ។
- o ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចឬផលិតផលសរុបក្នុងស្រុក កើនឡើងជាលំដាប់ហើយនឹងឈានចេញពីភាពក្រីក្រជាបណ្តើរៗ។

ទាំងនេះជាមូលហេតុដែលថវិកាជំនួយពីក្រៅប្រទេសសំរាប់អនុវត្តកម្មវិធីអេដស៍ត្រូវបានកាត់បន្ថយថវិកាជាបណ្តើរៗផងដែរ ។

- ស្ថិតក្នុងស្ថានភាពបែបនេះ រាជរដ្ឋាភិបាលកម្ពុជាជាក់ស្តែងបានដាក់ថវិកាជាតិចំនួន ៣,៧លានដុល្លាសំរាប់ឆ្នាំ ២០១៥ ដល់ ២០១៧ សំរាប់រួមចំណែកក្នុងការទិញឧសថ ARV ជាបដិភាពរបស់រាជរដ្ឋាភិបាលបន្ថែមលើមូលនិធិសាកល ។
- ទាក់ទងនឹងការងាររបាយការណ៍ជូនអង្គការសហប្រជាជាតិនេះ បន្ថែមលើរបាយការណ៍GARPR គឺយើងត្រូវធ្វើ របាយការណ៍អង្កេតការចំណាយ ប្រចាំឆ្នាំ National AIDS Spending Assessment (NASA) ដែលត្រូវធ្វើជារៀងរាល់ ២ ឆ្នាំម្តង ។ មកដល់ ពេលនេះ យើងនៅមិនទាន់មានប្រភពថវិកាសម្រាប់ការងារទាំងនេះសំរាប់ឆ្នាំបន្ទាប់ នេះនៅឡើយទេ ជាពិសេស ការធ្វើ NASA គឺត្រូវធ្វើនៅចុងឆ្នាំ ២០១៥ នេះ ។

ឆ្លងតាមបទអន្តរាគមន៍ខាងលើនេះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ឃើញថាសូចនាករ ទាក់ទងកម្មវិធីហើយកម្មវិធីទាក់ទងគោលនយោបាយហើយ គោលនយោបាយទាក់ទងថវិកា។

ទោះជាយ៉ាងណាក្តី ខ្ញុំសូមអំពាវនាវដល់អង្គសិក្ខាសាលទាំងមូលជួយពង្រឹងយន្តការជាតិតែមួយ សំរាប់ការត្រួតពិនិត្យនិងឆ្លើយតបទៅនឹងមេរោគអេដស៍និងក្នុងប្រទេសកម្ពុជា ។ ក្នុងន័យនេះ គ្រប់ស្ថាប័នរដ្ឋ និង ដៃគូរអភិវឌ្ឍន៍ដែលពាក់ព័ន្ធគួរធ្វើការរួមគ្នាលើសូចនាករ GARPR នេះ អោយបានល្អប្រសើរជាលំដាប់ ។ ក្នុងន័យនេះខ្ញុំសូម ឯកឧត្តម លោក ជំទាវ លោក លោកស្រី ជួយជំរុញអោយមាន គាំទ្រ និង ចូលផ្តល់ទិន្នន័យសម្រាប់បញ្ចូលទៅក្នុងរបាយការណ៍នេះឲ្យ មានគុណភាព និងឱ្យបានគ្រប់ជ្រុងជ្រោយ ។

ត្រង់ចំណុចនេះ ខ្ញុំសូមទាញចំណាប់អារម្មណ៍ចំពោះពាក្យពីរម៉ាត់គឺ ទិន្នន័យ និង ព័ត៌មាន ។ តើពាក្យពីរម៉ាត់នេះមានលក្ខណៈខុសគ្នាត្រង់ណា? ចំណុចដែលខុសគ្នានោះគឺត្រង់ន័យដែលថា” អ្នកអាចមានទិន្នន័យដោយគ្មានពត៌មាន ។ ប៉ុន្តែអ្នកមិនអាចមានព័ត៌មានដោយគ្មានទិន្នន័យបានឡើយ។ ”( You can have data without information, but you cannot have information without data) ។ ហេតុនេះរបាយការណ៍វឌ្ឍនភាពទៅដល់គោលដៅនៃការឆ្លើយ តបនឹងមេរោគអេដស៍មិនអាចធ្វើបានពេញលេញទេ បើប្រសិនណាគ្មានការចូលរួមផ្តល់ទាំង ទិន្នន័យ និងព័ត៌មានយ៉ាងសកម្មពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទេនោះ ។

មុននឹងបញ្ចប់ខ្ញុំសង្ឃឹមថា ឯកឧត្តម លោក ជំទាវ លោក លោកស្រី អ្នកនាងកញ្ញា នឹងផ្តល់យោបល់ និង បំពេញបន្ថែមនូវចំណុចខ្វះខាតនានា ក្នុងរបាយការណ៍នេះដើម្បីបង្កើនគុណភាពល្អបំផុត ។ ព្រោះយើងត្រូវបញ្ចូលរបាយការណ៍នេះទៅក្នុងវប្រព័ន្ធអនឡាញ (online) ឲ្យបានមុនថ្ងៃទី ១៥ ខែ មេសា ខាងមុខនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះការអញ្ជើញចូលរួមរបស់ ឯកឧត្តម លោក ជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់ ។ ក្នុងឱកាសចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នេះដែរសូមជូនពរជ័យ សិរីមង្គល វិបុលសុខ កុំបី ឃ្លាងឃ្លាតឡើយ ។

សូមប្រកាសបើកអង្គសិក្ខាសាលា” ផ្ទៀងផ្ទាត់លទ្ធផលនៃការរៀបចំរបាយការណ៍សកលនៃការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា” ចាប់ពីពេលនេះតទៅ ៕

សូមអរគុណ